ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

# លក្ខន្តិកស្តីពីភារៈកិច្ចសម្រាប់សាស្ត្រាចារ្យស្រាវជ្រាវ

# នៃ

# វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

*យោង ៖*

- *សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា លេខ៣៦សរច ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៨១ស្តីពីការបង្កើតវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់កម្ពុជា សូវៀត*
- *លក្ខន្តិករបស់ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា*

## សម្រេច

*ប្រការ ១ ៖ អ្នកស្រាវជ្រាវវិទ្យាសាស្ត្រគឺជាសាស្ត្រាចារ្យ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (វ.ប.ក) ដែលត្រូវបានជ្រើសរើសតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖*

- មានចំណង់ចំណូលចិត្ត និងគំនិតផ្តួចផ្តើមក្នុងការងារស្រាវជ្រាវវិទ្យាសាស្ត្រ
- ត្រូវមានសញ្ញាប័ត្រចាប់ពីថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ឡើងទៅ
- មានអាកប្បកិរិយា សីលធម៌រស់នៅ និងទំនាក់ទំនងល្អ

*ប្រការ ២ ៖ ការជ្រើសរើសសាស្ត្រាចារ្យស្រាវជ្រាវវិទ្យាសាស្ត្រជាបន្ទុករបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រ វ.ប.ក ។ បេក្ខជនត្រូវដាក់ពាក្យស្នើសុំមកក្រុមប្រឹក្សាវិទ្យាសាស្ត្រ វ.ប.ក ។*

*ប្រការ ៣ ៖ ក្រុមប្រឹក្សាវិទ្យាសាស្ត្រមានសមាសភាពដូចខាងក្រោម ៖*

- *គណៈកម្មាធិការនាយកវិទ្យាស្ថាន*
- *ប្រធានដេប៉ាតឺម៉ង់ទាំងអស់*
- *អ្នកទទួលបន្ទុកកិច្ចការស្រាវជ្រាវវិទ្យាសាស្ត្រនៅតាមដេប៉ាតឺម៉ង់*

- សមាជិកនៃក្រុមអ្នកជំនាញពិគ្រោះយោបល់អន្តរជាតិសំរាប់វិទ្យាស្ថាន។

ប្រការ ៤ ៖ សាស្ត្រាចារ្យស្រាវជ្រាវវិទ្យាសាស្ត្រត្រូវមានភារៈកិច្ច ៖

- បំពេញការងារបង្រៀនប្រចាំឆ្នាំ យ៉ាងច្រើន ១៩២ ម៉ោង បន្ថែមលើការងារស្រាវជ្រាវ
- ធានានិរន្តរភាពនៃដំណើរការស្រាវជ្រាវវិទ្យាសាស្ត្រ
- ធ្វើរបាយការណ៍ប្រចាំខែជូនក្រុមប្រឹក្សាវិទ្យាសាស្ត្រ វ.ប.ក
- ធ្វើទំនាក់ទំនងផ្ទាល់ជាមួយស្ថាប័ននានា ដើម្បីទាញយកគំរោងស្រាវជ្រាវ
- ចូលរួមក្នុងការងារដឹកនាំគំរោងនិក្ខេបបទ សំរាប់ថ្នាក់អនុបណ្ឌិត និងវិស្វករ
- ចូលរួមក្នុងសន្និសីទស្រាវជ្រាវវិទ្យាសាស្ត្រ
- បោះពុម្ពផ្សាយនូវលទ្ធផលស្រាវជ្រាវក្នុងព្រឹត្តិប័ត្រវិទ្យាសាស្ត្រជាតិ ឬ អន្តរជាតិ
- ចូលរួមក្នុងកិច្ចការសេវាសាធារណៈតាមដេប៉ាតឺម៉ង់

ប្រការ ៥ ៖ សាស្ត្រាចារ្យស្រាវជ្រាវវិទ្យាសាស្ត្រនឹងទទួលបាន៖

- ប្រាក់ឧបត្ថម្ភ
- ការលើកទឹកចិត្តក្នុងការទាញយកគំរោងស្រាវជ្រាវ
- ការលើកទឹកចិត្តក្នុងការបោះពុម្ពផ្សាយកិច្ចការស្រាវជ្រាវ

ប្រការ ៦ ៖ សាស្ត្រាចារ្យស្រាវជ្រាវត្រូវចុះកិច្ចសន្យាជាមួយ វ.ប.ក ក្នុងអំឡុង ៦ខែម្តង។

ប្រការ ៧ ៖ វ.ប.ក មានសិទ្ធកែប្រែលក្ខន្តិកនេះក្នុងករណីចាំបាច់ ។

ប្រការ ៨ ៖ សាស្ត្រាចារ្យស្រាវជ្រាវ វ.ប.ក ត្រូវគោរពនូវលក្ខន្តិកក្នុងនេះឱ្យមានប្រសិទ្ធភាពខ្ពស់

ប្រការ ៩ ៖ លក្ខន្តិកនេះមានប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១០

នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

Institut de Technologie du Cambodge

បណ្ឌិត អ៊ុំ រម្យណី

ចម្លងជូន:

- ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- គណៈគ្រប់គ្រងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- ឯកសារ វ.ប.ក